

# មេរោគក្លូ៉ណាដ៏ជាប់ស្អិត

Jelena Angela M. Fagutao

Yoj Dominic Borbon, Daniel Maverick Angelo Borbon

Let's Read

The Asia Foundation



នៅឯដែនដីវីរុស មានគ្រួសារដ៏គួរឱ្យខ្លាចមួយរស់នៅឈ្មោះថា មេរោគក្សួណា។



នារដូវត្រជាក់ខែធ្នូ ឆ្នាំ២០១៩ មានមេរោគថ្មីមួយបាន ចាប់កំណើតក្នុងគ្រួសារនេះ។ ពួកគេបានដាក់ឈ្មោះវាថា កូរ៉ូណា ជាប់ស្និត។



ពេលធំឡើងកាលណា ជាប់ស្អិត បានឮតែរឿងអាក្រក់ៗដ៏គួរឱ្យខ្លាចអំពីបុព្វបុរសខ្លួន។ វាក៏បានស្តាប់ឮចាស់ៗនៅក្នុងគ្រួសារវានិយាយគ្នាអំពីជំងឺកាចសាហាវដ៏គួរឱ្យខ្លាចផ្សេងៗ ដែលជាគូប្រជែងរបស់ពួកគេផងដែរ...



...ជំងឺផ្តាសាយអេស្ប៉ាញឆ្នាំ១៩១៨។ គូប្រជែងមួយនេះត្រូវបានគេស្គាល់ថាជាជំងឺផ្តាសាយរាតត្បាតដ៏សាហាវបំផុតនៅឆ្នាំ១៩១៨ ដែលបានឆ្លង និងឆក់យកជីវិតមនុស្សរាប់លាននាក់នៅក្នុងពិភពមនុស្ស។ គ្មានសមាជិកណាម្នាក់ក្នុងគ្រួសារជាប់ស្អិត អាចប្រជែងយកឈ្នះលើចំនួនអ្នកស្លាប់ដោយសារជំងឺផ្តាសាយរាតត្បាតនេះបានឡើយ។



រហូតដល់ពេល ជាប់ស្អិត ចូលមកដល់។ វាបានគិតថា វាត្រូវតែធ្វើឱ្យមនុស្សទាំងអស់ភ័យខ្លាចចំពោះក្រុមគ្រួសារវាម្តងទៀត។ ”គ្រួសាររបស់ខ្ញុំធ្លាប់តែល្បីឈ្មោះខាងសម្លាប់ជីវិតមនុស្ស។ ខ្ញុំត្រូវតែធ្វើឱ្យបាន! ខ្ញុំនឹងចម្លងមនុស្សរាប់លាននាក់ ហើយគ្រួសារខ្ញុំនឹងមានមោទនភាពចំពោះខ្ញុំ” ។



ជាប់ស្អិត បានរត់ចេញពីដែនដីវីរុស ដោយមិនប្រាប់នរណាទាំងអស់។ វាបាននឹកឃើញដល់រឿងជោគជ័យដ៏អស្ចារ្យនៅពេលវាត្រលប់មកផ្ទះវិញថែមទៀតផង។



វាបានធ្វើដំណើរយ៉ាងវែងឆ្ងាយ ហើយទីបំផុតវាក៏បានទៅដល់គោលដៅ គឺដែនដីសរីរាង្គ។ ដែនដីសរីរាង្គ ពោរពេញទៅដោយសរីរាង្គជាច្រើន។ មេដឹកនាំនៅទីនោះគឺភ្នែក ដៃ ច្រមុះ មាត់ និងបេះដូង ហើយតួនាទីសំខាន់បំផុតរបស់ពួកគេ គឺត្រូវការពារសួតដ៏ទន់ខ្សោយ។



ដំណឹងអំពីការមកដល់របស់ ជាប់ស្និត បានបង្កការភ័យខ្លាចនៅដែនដីសរីរាង្គ។ ពួកគេស្រមៃដល់សំឡេងសើចលាន់រំពងដ៏គួរឱ្យខ្លាចតាមព្រំដែននៃដែនដីសរីរាង្គ ហើយសរីរាង្គទាំងអស់ភ័យឡើងញ័រខ្លួន។



”រឿងនេះ នឹងក្លាយជាបញ្ហាធំមិនខានទេ! តើយើងត្រូវធ្វើយ៉ាងណាដើម្បីទប់ស្កាត់កុំឱ្យមេរោគចូលមកក្នុងដែនដីសរីរាង្គបាន?” ច្រមុះ បាននិយាយដោយក្តីភ័យខ្លាច។



មាត់បាននិយាយថា ”តើយើងធ្វើយ៉ាងណាទើបអាចរួចជីវិតពីសមរភូមិនេះ?! ពួកយើងត្រូវតែការពារស្ងួតឱ្យបាន ព្រោះ នាងមិនអាចទប់ទល់នឹងការវាយប្រហារនេះបានទេ។”



សំជាសាប៊ូលាងដៃ បាននិយាយថា ”កុំបារម្ភ! មេរោគនោះមិន អាចធ្វើអ្វីយើងទេ!” ពួកគេទាំងអស់គ្នាក៏ចាប់ផ្ដើមធ្វើការ។



អានតូនី ជាទឹកអាល់កុល បានប្រាប់ទៅដៃថា ”កុំប៉ះពាល់អ្វីទាំងអស់! ឯងត្រូវតែរក្សាអនាម័យខ្លួនឯងជានិច្ច។”



សំ ជាសាប៊ូលាងដៃ ក៏បានបន្តថា ”ច្រមុះ! ឯងត្រូវតែកណ្តាស់ ដាក់ក្រដាសជូតមាត់ជានិច្ច! បែបនេះតំណក់សារធាតុរាវតូចៗ របស់ឯងមិនខ្ចាតផ្តេសផ្តាសទេ។”



សាប៊ូ និងទឹកអាល់កុល បានប្រាប់ទៅមាត់ថា "ឯងត្រូវផឹកទឹក និងញ៉ាំបន្លែផ្លែឈើជាប្រចាំ!"



ដៃ មិនអាចទ្រាំនៅស្ងៀមបានទេ។ ពួកគេចេះតែចង់ប៉ះនេះ ប៉ះនោះមិនឈប់ ពិសេសចង់ឈោងទៅឱបមិត្តរបស់ពួកគេ។ ដៃទាំងពីរ បាននិយាយថា ”ពួកយើងមិនអាចទ្រាំបានទៀតទេ! ពួកយើងពិបាកធ្វើតាមណាស់!”



អាល់កុល និងសាប៊ូលាងដៃ បានកោះហៅមិត្តជំនាញខាងសម្អាតឯទៀតមកដែរ។ ពួកគេទាំងអស់គ្នា បានរៀបចំឧបករណ៍រៀងៗខ្លួន ដើម្បីប្រុងប្រៀបទប់ទល់។ ពួកគេត្រូវបានបញ្ជាឱ្យបិទព្រំដែនទាំងអស់ដើម្បីរារាំងកុំឱ្យមេរោគចង្រៃដ៏គួរឱ្យស្អប់ចូលមកក្នុងដែនដីសរីរាង្គបាន។ ទឹកអាកុល បាននិយាយថា "ពួកយើងមកដល់ហើយ តោះ! ប្រញាប់ឡើង!"



នៅពេលមកដល់ព្រំដែន ពួកគេបានជួបមេរោគចម្លែករូបរាងអាក្រក់មួយ។ ជាប់ស្អិត បាននិយាយថា " ថាទៅមើល តើយើងជាអ្នកណា?"

សាប៊ូ បានពោលថា "អូ! ឯងគឺជាមេរោគដ៏សាហាវដែលសរីរាង្គកំពុងនិយាយនោះហើយ!"

ជាប់ស្អិត បានតបថា "គឺជំងឺសារស៍ជំនាន់ទី២ តែមួយគត់!"



ក្រុមសម្អាតទាំងអស់បានប្រយុទ្ធជាមួយ ជាប់ស្អិត ដោយប្រើអាវុធកម្ចាត់មេរោគរបស់ខ្លួន។ ប៉ុន្តែ ជាប់ស្អិត ខ្លាំងពិបាកទប់ទល់ណាស់។ ក្រុមសម្អាត ត្រូវបានជាប់អន្ទាក់ ប៉ុន្តែពួកគេត្រូវធ្វើយ៉ាងណាមិនឱ្យ ជាប់ស្អិត ឆ្លងចូលបានឡើយ។ ពួកគេត្រូវតែការពារសួត។

"ពួកយើងគ្មានជម្រើសណាក្រៅពីត្រូវប្រយុទ្ធជាមួយវាទេ" អាកុលបាននិយាយ។

នៅពេល ជាប់ស្អិត បានមកទំលើដៃទាំងពីរ វាក៏ចាប់ផ្តើមតោងឡើង ប៉ុន្តែវាមិនអាចនៅទីនោះបានយូរទេ។ ដៃទាំងពីរ បានស្រែកថា "អានតូនី ពួកយើងត្រូវការឯង!"

អានតូនី បានបាញ់ស្រោចទឹកអាល់កុល៧០% ចេញពីលើក្បាលរបស់វា។

”សំ ខ្ញុំត្រូវការឯងជួយ!” អាល់កុល ស្រែក។



សាប៊ូលាងដៃ ក៏ប្រញាប់ប្រញាល់ទប់ទល់ដោយប្រើពពុះសម្លាប់មេរោគដ៏ខ្លាំងក្លាចេញពីរាងកាយរអិលរបស់ខ្លួន។ ជាប់ស្អិតបានដកថយ។ ខ្លួនវាត្រូវសើមជោកដោយអំណាចដ៏ខ្លាំងក្លារបស់ភ្លើងធំបំផ្លាញមេរោគ។ វាដួលទៅក្រោយ ចុះខ្សោយកម្លាំងហើយក៏បរាជ័យ។ វាបានព្យាយាមស្វែងរកដែនដីផ្សេងទៀតដើម្បីលុកលុយ។



ជាប់ស្អិត បានរត់ចេញពីដែនដីសរីរាង្គទាំងទឹកភ្នែក។ ភ្នាក់ងារត្រួតពិនិត្យស្បែក ដែលជានគរបាលដែនដីសរីរាង្គបានឃាត់ខ្លួនវា ហើយបណ្ដេញចេញពីច្រកទ្វារស្រទាប់ស្បែកក្រៅរបស់ពួកគេ។ ជាប់ស្អិត បានបាក់ទឹកចិត្តយ៉ាងខ្លាំង។ វាក៏ចាប់ផ្ដើមធ្វើដំណើរត្រលប់ទៅផ្ទះវិញយ៉ាងគួរឱ្យអាណិត។ គ្រួសាររបស់វាបានមកទទួលវានៅខ្លោងទ្វារ ហើយបាននិយាយជាមួយវាថា ”ជាប់ស្អិត! ពួកយើងមិនអាចយកឈ្នះពួកសរីរាង្គបានទេ។ ពួកយើងត្រូវនៅក្នុងដែនដីវីរុសរបស់ពួកយើងវិញ។ ពួកសរីរាង្គតែងតែរិះរកវិធីដើម្បីកម្ចាត់ពួកយើង។”



ពួកសរីរាង្គនៅដែនដីសរីរាង្គ ក៏បានរស់នៅស្អាត និង សប្បាយរីករាយ ចំណែកឯស្ទួតក៏បន្តរស់នៅយ៉ាងសុខសាន្ត ចាប់តាំងពីពេលនោះមក។ សរីរាង្គទាំងអស់ បាននិយាយព្រមគ្នាថា "សូមកុំភ្លេចលាងដៃរបស់អ្នក និងរក្សាអនាម័យជានិច្ច!"

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Clingy the Virus*, Author: Jelena Angela M. Fagutao. Illustrator: Yoj Dominic Borbon, Daniel Maverick Angelo Borbon. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Somey Chheang and Chou Chinith